នាយកដ្ឋានជលផល
វិទ្យាស្ថានស្រាវជ្រាវ និង
អភិវឌ្ឍន៍នេសាទទឹកសាប

# សេចក្តីថ្លែងការណ៍ក្រុងព្រះសីហនុស្តីពីវិស័យជលផល

WorldFish CENTER

ត្រីធ្លាប់មានតួនាទីដ៏សំខាន់ស្រម្រាប់ប្រជាជនកម្ពុជាជាយូរណាស់មកហើយព្រោះថា វាជាប្រភពអាហារូបត្ថម្ភចំបងនៅក្នុងរបបអាហារប្រចាំថ្ងៃ ប្រភពប្រាក់ចំណូលសំខាន់ ហើយមានសារៈសំខាន់ ជាពិសេសខាងវប្បធម៌ និង សាសនាទៀតផង។ វិស័យជលផលមានទំនាក់ទំនងជាមួយប្រជាពលរដ្ឋជាច្រើនលាននាក់នៅក្នុងប្រទេស ជាពិសេសអ្នកដែលរស់នៅតាមដងទន្លេជុំវិញបឹងទន្លេសាប និង នៅតាមតំបន់ឆ្នេរ ។



សមាជិក សមាជិកានៃអង្គសន្និសីទចំនួន **៧១រូប** ជាតំណាងឱ្យស្ថាប័នរដ្ឋាភិបាល វិទ្យាស្ថានស្រាវជ្រាវ អាជ្ញាធរដែនដី សហគមន៍នេសាទ និង តំណាងឱ្យអង្គការអន្តរជាតិ និង អង្គការសង្គមស៊ីវិល ដែលមានវត្តមាននៅក្នុងសន្និសីទជាតិស្តីពី **"ការផ្តល់អាទិភាពលើវិស័យជលផលកម្ពុជាសម្រាប់កិច្ចអភិវឌ្ឍន៍ និង ទស្សនវិស័យរបស់សហគមន៍នេសាទ"** ដែលបានធ្វើឡើងនៅក្រុងព្រះសីហនុ ពីថ្ងៃទី១៤-១៥ ខែកុម្ភៈ ឆ្នាំ២០០៦ ដែលរៀបចំឡើងដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាបនៃនាយកដ្ឋានជលផល សហការជាមួយ មជ្ឈមណ្ឌលត្រីពិភពលោក និង វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា។



## យើងមានការប្តេជ្ញា

**ដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃត្រី និង វិស័យជលផល សំរាប់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា និង សេដ្ឋកិច្ចជាតិ ហើយប្តេជ្ញាធ្វើការដើម្បីធានាថា ការគ្រប់គ្រង និង ការពារធនធានជលផល ត្រូវបានយកមកពិចារណាសម្រាប់ដាក់បញ្ចូលទៅក្នុងគោលនយោបាយនៃការអភិវឌ្ឍន៍នៅតាមមូលដ្ឋាន និង សេដ្ឋកិច្ចជាតិ។**

ត្រី និង វិស័យជលផលផ្តល់នូវអត្ថប្រយោជន៍ដ៏ច្រើនដល់គ្រួសារនីមួយៗ និង សេដ្ឋកិច្ចជាតិ ហើយមានលក្ខណៈធំធេងជាងអ្វីដែលប្រជាពលរដ្ឋភាគច្រើនបានដឹងទៅទៀត។ វិធីសាស្ត្រនានាដែលធ្លាប់បានប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃអំពីការរួមចំណែករបស់វិស័យជលផលដល់សេដ្ឋកិច្ចជាតិ និង ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដូចជាការរួមវិភាគទានរបស់វិស័យនេះចំពោះផលទុនជាតិសរុបក្នុងស្រុក ឬ ចំពោះការបរិភោគជាមធ្យមរបស់បុគ្គលម្នាក់ៗបានឆ្លុះបញ្ចាំងត្រឹមតែចំណែកមួយប៉ុណ្ណោះនៃតម្លៃពេញលេញរបស់ត្រី និង វិស័យជលផលនៅក្នុងប្រទេសកម្ពុជា។ តម្លៃពិតប្រាកដរបស់ត្រីមានទំហំធំធេងមិនអាចសំដែងចេញជាសាច់ប្រាក់ និង ជាតម្លៃរូបវ័ន្តបានឡើយ។



ការបង្កើតសហគមន៍នេសាទ គឺជាការផ្លាស់ប្តូរគួរឱ្យកត់សំគាល់នៅក្នុងការគ្រប់គ្រងធនធានជលផលនៅក្នុងប្រទេសកម្ពុជា។ ការអភិវឌ្ឍន៍ដែលគួរឱ្យចាប់អារម្មណ៍ មិនត្រឹមតែជួយរក្សាការពារប្រព័ន្ធធនធានជលផល និង បង្កើនផលត្រីនៅក្នុងប្រទេសតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកកំពស់ការរស់នៅរបស់ប្រជាពលរដ្ឋតាមរូបភាពជាច្រើន (ឧទាហរណ៍ មាគ៌ាមួយដែលអាចទុកចិត្តបាននៃការអភិវឌ្ឍន៍ គឺជាការបន្ថែមតម្លៃទៅលើផលត្រី និង ការកែច្នៃផលនេសាទ ដើម្បីផ្គត់ផ្គង់តាមកំណើននៃតម្រូវការនៅលើទីផ្សារក្រោយពីកម្ពុជាចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក)។



## ដោយផ្អែកលើមនសិការ និង ចំណុចនានានៃកង្វល់ខាងលើ យើងអះអាងថា:

ដើម្បីផ្តល់អាទិភាពលើវិស័យជលផលនៅក្នុងបរិបទនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិកម្ពុជាយើងត្រូវតែ :

- ធ្វើការឱ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីធ្វើឱ្យអ្នកកសាងផែនការ អ្នកនយោបាយ និង អ្នកធ្វើសេចក្តីសម្រេចចិត្តនានានៅគ្រប់លំដាប់ថ្នាក់ទទួលស្គាល់អំពីតម្លៃពិតនៃត្រី និង វិស័យជលផលចំពោះប្រទេសយើង ហើយប្តេជ្ញាចិត្តចូលរួមគាំទ្រ ថែរក្សា និង ការពារធនធានជលផល។
- ធ្វើឱ្យប្រាកដថា មាតាបិតា និង គ្រូបង្រៀនធ្វើការគូសបញ្ជាក់ប្រាប់ដល់សិស្ស និង កូនចៅអំពីសារៈសំខាន់នៃការថែរក្សាព្រៃលិចទឹក ព្រៃកោងកាង និង ផ្លូវទឹកនានា ដើម្បីធ្វើឱ្យនៅតែមានត្រីជាបន្ត ។
- រៀនសូត្រឱ្យកាន់តែច្រើនបន្ថែមទៀតអំពីលក្ខខណ្ឌដែលចាំបាច់ដើម្បីឱ្យពូជត្រីនៅក្នុងស្រុករបស់យើងលូតលាស់បាន និង ជួយធ្វើឱ្យប្រជាពលរដ្ឋថែរក្សា និង ការពារធនធានជលផលដ៏មានតម្លៃរបស់ប្រទេសជាតិឱ្យបានល្អប្រសើរជាងមុន។
- យល់ដឹងថា សកម្មភាពនានានៅក្រៅព្រំដែនរបស់ប្រទេសយើងមានឥទ្ធិពលអវិជ្ជមានបែបណាមកលើការផ្គត់ ផ្គង់ត្រីនៅក្នុងប្រទេស និង កៀងគរឱ្យមានការគាំទ្រ និង ចូលរួមជាសាធារណៈ ដើម្បីឆ្លើយតបចំពោះផលវិបាកទាំងនេះ។
- ស្រាវជ្រាវ និង កំណត់អំពីអត្ថប្រយោជន៍សេដ្ឋកិច្ច និង វប្បធម៌សង្គម ចេញពីការនេសាទដែលជាផ្នែកសំខាន់មួយនៃការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។
- កំណត់អាទិភាពស្រាវជ្រាវរបស់យើង ដើម្បីគូសបញ្ជាក់ឱ្យបានប្រសើរជាងមុនអំពីការរួមចំណែកពិតប្រាកដនៃវិស័យជលផលចំពោះសេដ្ឋកិច្ចរបស់ប្រទេស។



ដើម្បីផ្តល់អាទិភាពលើវិស័យជលផល នៅក្នុងបរិបទនៃទស្សនវិស័យរបស់សហគមន៍របស់យើង យើងត្រូវតែ :

- កសាងសមត្ថភាព និង ផ្តល់អំណាចឱ្យសហគមន៍នេសាទ ដើម្បីក្លាយខ្លួនទៅជាអ្នកសហគ្រប់គ្រងធនធានជលផលដ៏សកម្ម និង មានប្រសិទ្ធិភាព។
- លើកកំពស់ការគ្រប់គ្រងនូវធនធានជលផល និង កន្លែងនេសាទដែលបានកាត់ចេញពីឡូតិ៍នេសាទដោយសហគមន៍ និង ផ្តល់ឱ្យប្រជាពលរដ្ឋមូលដ្ឋាននូវមធ្យោបាយដើម្បីទទួលផលពីការគ្រប់គ្រងនោះ។
- វាយតម្លៃអំពីអត្ថប្រយោជន៍ជាច្រើនដែលកើតចេញពីការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្នុងការធ្វើនេសាទ និង ការចាត់ចែងនៅមូលដ្ឋាន ដើម្បីធានាថាសិទ្ធិអំណាចបែបនេះមិនត្រូវបានដកហូតឡើយ។
- ស្វែងរកវិធីដើម្បីពង្រីកតួនាទីរបស់ស្ត្រីនៅក្នុងផលិតកម្មផលិតផលជលផល និង ការធ្វើចរាចរផលិតផលជលផលនៅលើទីផ្សារ ដើម្បីបង្កើនអត្ថប្រយោជន៍ចំពោះស្ត្រី និង គ្រួសាររបស់ពួកគាត់។
- បង្កើតឱ្យមានរបៀបចាត់ចែងថ្មីសម្រាប់ស្ថាប័នដែលអាចពង្រឹងជំហរស្វ័យភាពសេដ្ឋកិច្ច និង បង្កើនជំនឿទុកចិត្តក្នុងចំណោមសហគមន៍លើសមត្ថភាពរបស់ខ្លួនក្នុងការលើកកំពស់គុណភាពនៃជីវិតរស់នៅក្នុងមូលដ្ឋាន។
- ធ្វើឱ្យប្រជាពលរដ្ឋពាក់ព័ន្ធនៅក្នុងការស្រាវជ្រាវរបស់យើង ពិសេសអ្នកដែលនឹងទទួលឥទ្ធិពលពីការស្រាវជ្រាវនោះដោយដកស្រង់ចំណេះដឹងនៅមូលដ្ឋាន និង បង្កើតបរិយាកាសដែលឱ្យតម្លៃទៅលើទស្សនវិស័យខុសៗគ្នា។
- ធ្វើការជិតស្និទ្ធបន្ថែមទៀតជាមួយក្រុមប្រឹក្សាឃុំ/សង្កាត់ ស្ថាប័នរដ្ឋាភិបាល និង អង្គការសង្គមស៊ីវិលផ្សេងទៀត ដើម្បីធានាថា ការពាក់ព័ន្ធរបស់សហគមន៍នៅក្នុងការគ្រប់គ្រងជលផលនឹងជួយបង្កើនធម្មនុញ្ញភាព និង ការគាំទ្រខាងនយោបាយ។





ដោយចងចាំនូវសំណើសកម្មភាពទាំងឡាយដែលបានលើកឡើងខាងលើ និង ទទួលស្គាល់អំពីកិច្ចប្រឹងប្រែងជាបន្ត យើងត្រូវតែប្រឹងប្រែងដើម្បីសម្រេចគោលដៅនេះឱ្យបាន។ យើងជាអ្នកចូលរួមនិងជាតំណាងឱ្យផ្នែកនានានៅក្នុងប្រទេស ធ្វើការអះអាងអំពីការប្តេជ្ញារបស់យើងនៅក្នុងសេចក្តីថ្លែងការណ៍ក្រុងព្រះសីហនុ ស្តីពីវិស័យជលផល និង សន្យាធ្វើការលើកកំពស់ការប្តេជ្ញានេះទៅអនាគតដែលជាចេតនារួមគ្នារបស់យើង ដើម្បីផ្តល់អាទិភាពលើវិស័យជលផលកម្ពុជាសម្រាប់កិច្ចអភិវឌ្ឍន៍ និង ទស្សនវិស័យរបស់សហគមន៍នេសាទ។


**គាំទ្រដោយ**

ADB
ADB TA 4563-CAM
ការកសាងសមត្ថភាព នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍នេសាទទឹកសាប (វគ្គ២)



អាសយដ្ឋាន វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍នេសាទទឹកសាប នាយកដ្ឋានជលផល: អាគារលេខ ១៨៦, មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា, ប្រអប់សំបុត្រលេខ ៥៨២, ទូរស័ព្ទ/ទូរសារ: (៨៥៥) ២៣ ២២០ ៨១៧, អ៊ីម៉ែល: info@ifredi.org គេហទំព័រ: www.ifredi.org

រៀបរៀងដោយ: សូ ណាម ជួប សុខន និង ឡេង ស៊ីវណ្ណ